# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តឧត្តរមានជ័យ

សាលក្រមព្រហ្មទណ្ឌ

-លេខ: **៤១ "ក" / ១១៦**
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ: ២៦៧
ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ: ១៩១
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣
-ជំនុំជម្រះលេខ:០៨៨
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

-បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម ០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

-បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តឧត្តរមានជ័យនាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង០៨:៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តឧត្តរមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

### មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**១.**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:**២៦៧** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ដែលមានសាវតារជាតិជនជាប់ចោទ ដូចខាងក្រោម៖

**១.១.**ជនជាប់ចោទឈ្មោះ[redacted] **សិទ្ធ** ហៅក្រៅ**សិទ្ធិ** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តបាត់ដំបង កាន់សាសនាព្រះពុទ្ធ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ[redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ[redacted] **ហៀត** មានកូនចំនួន០២នាក់ ឪពុកឈ្មោះ **សន** (ស្លាប់) ម្តាយឈ្មោះ **ផល** (រស់) ជានីតិជន ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ: **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅចំនុចភូមិបុស្សថ្មី សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងបញ្ញត្តិនិងផ្តន្ទាទោសតាមមាត្រា **២៧**,មាត្រា **១៩៩** និងមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

**១.២.**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធី** ភេទប្រុស អាយុ ៣៥ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្ននៅភូមិបុស្សថ្មី សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។

## ២.**អង្គហេតុនៃរឿងមានដូចតទៅ**

**២.១.សង្ខេបអង្គហេតុ៖**កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ឈ្មោះ [redacted] សិទ្ធ បានមកផ្ទះរបស់ឈ្មោះ [redacted] ធី ដែលមានទីតាំងស្ថិតនៅភូមិបុស្សថ្មី សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ហើយក៏បានទាស់ពាក្យសម្តីនឹងគ្នាពេលនោះឈ្មោះ [redacted] សិទ្ធ ក៏បានហៅឲ្យឈ្មោះ [redacted] ធី ចេញក្រៅផ្ទះ ពេលដែលឈ្មោះ [redacted] ធី ចេញមកស្រាប់តែឈ្មោះ [redacted] សិទ្ធ ធ្វើសកម្មភាពវាយមួយដៃចំកំភ្លែកខាងស្តាំ និងចាប់បោកនឹងដីជាច្រើនលើកច្រើនសាររួចក៏ចាប់អូសឈ្មោះ [redacted] ធី ទៅប្រឡាយទឹកមុខផ្ទះ និងចាប់ករបស់ឈ្មោះ [redacted] ធី ជ្រមុជទឹកចូលក្នុងប្រឡាយនោះ ស្របពេលនោះឈ្មោះ [redacted] ហាំ បានមកដល់ ឃើញដូចនេះឈ្មោះ [redacted] ហាំ បានជួយឃាត់ទើបឈ្មោះ [redacted] សិទ្ធ បញ្ឈប់សកម្មភាពនោះវិញ។

**២.២.បានឃើញ** ពាក្យបណ្តឹងលេខ: **១៩៤៥** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **ធី**។

**២.៣.បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:**២០៥** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ តំណាងអយ្យការ បានសម្រេចបើកការស៊ើបសួរលើជនត្រូវចោទឈ្មោះ [redacted] **សិទ្ធ** ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទ: **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២១៧,២៧** និងមាត្រា **១៩៩** នៃក្រមព្រហ្មទណ្ឌ។

**២.៤.បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ:**០៦០** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] **សិទ្ធ** ហៅក្រៅ **សិទ្ធិ** ភេទប្រុស អាយុ ៣៨ឆ្នាំ **ទៅជំនុំជម្រះ**ពីបទ: **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២១៧,២៧** និងមាត្រា **១៩៩** នៃក្រមព្រហ្មទណ្ឌ។

**២.៥-បានឃើញ** ដីកាដំណោះស្រាយលេខ: **០៥៥/២៣** ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] **សិទ្ធ** ហៅក្រៅ **សិទ្ធិ** ភេទប្រុស អាយុ ៣៨ឆ្នាំ **ទៅជំនុំជម្រះ** ពីបទ: **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

## ៣.**នាពេលសវនាការ**

**៣.១.**តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធី** បានឆ្លើយថា: កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ឈ្មោះ [redacted] សិទ្ធ បានពាក់ស្បែកជើងម្តាយខ្ញុំឈ្មោះ [redacted] ចន្ទី យកទៅបាត់ដោយពុំបានប្រាប់មួយម៉ាត់ លុះរហូតមកដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១៨ និង៣០នាទី ឈ្មោះ [redacted] សិទ្ធ បានមកផ្ទះរបស់ខ្ញុំបាទ ហើយពេលនោះខ្ញុំបាទក៏បានទារយកស្បែកជើងនោះពីគាត់វិញ ប៉ុន្តែឈ្មោះ [redacted] សិទ្ធ បានប្រកែកថា ពុំបានយកស្បែកជើងម្តាយខ្ញុំបាទទេ ខ្ញុំបាទបានប្រាប់គាត់ថាឃើញច្បាស់ណាស់ គឺគាត់យកស្បែកជើងម្តាយរបស់ខ្ញុំបាទ តែគាត់ប្រកែកថាមិនបានយក បន្តិចក្រោយមកគាត់ក៏ប្រាប់ខ្ញុំបាទឲ្យមកមើលស្បែកជើងនៅក្រៅផ្ទះ ពេលខ្ញុំបាទដើរចេញទៅក្រៅផ្ទះភ្លាមស្រាប់តែឈ្មោះ [redacted] សិទ្ធ បានធ្វើសកម្មភាពវាយខ្ញុំបាទមួយដៃចំកំភ្លែកខាងស្តាំបណ្តាលឲ្យរងរបួសបែកឈាម និងចាប់បោក ព្រមទាំងអូសខ្ញុំបាទទៅប្រឡាយខាងមុខផ្ទះ រួចក៏បានចាប់ខ្ញុំបាទជ្រមុជទឹកក្នុងប្រឡាយនោះ ភ្លាមនោះក៏មានឈ្មោះ [redacted] ហាំ ភេទប្រុស អាយុ១៧ឆ្នាំ បានមកជួយឃាត់ទាន់ កុំអី



Scanned with CamScanner

ខ្ញុំបាទបានស្លាប់បាត់បង់ជីវិតទៅហើយ។ ក្រោយពីកើតហេតុភ្លាម ខ្ញុំបាទបានទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ អស់ប្រាក់ប្រហែល៦០ម៉ឺនរៀល មានវិក័យបត្រខ្លះអត់វិក័យបត្រខ្លះ នៅក្នុងរឿងនេះខ្ញុំបាទសូមទាមទារសំណងជម្ងឺចិត្តចំនួន ១២.០០០.០០០(ដប់ពីរលាន)រៀល។

**៣.២.**តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ចន្ធី** បានឆ្លើយថា:កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ពេលដែលខ្លួនកំពុងអង្គុយនៅផ្ទះនៅភូមិបុស្សថ្មី សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ស្រាប់តែឃើញឈ្មោះ [redacted] សិទ្ធ ទៅរកឈ្មោះ [redacted] ធី ប៉ុន្តែមិនដឹងថាគាត់រកធ្វើអ្វីទេ ពេលដែលរកមិនឃើញក៏ឈ្មោះ [redacted] សិទ្ធ ទៅរកឈ្មោះ [redacted] ធី បានដើរទៅក្រោយផ្ទះនាងខ្ញុំ។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] សិទ្ធ ក៏បានហៅឈ្មោះ [redacted] ធី ឱ្យចេញក្រៅផ្ទះវិញម្តងពេលនោះឈ្មោះ [redacted] ធី ក៏បានដើរចេញតាមពេលមកដល់ក្រៅភ្លាមស្រាប់តែឈ្មោះ [redacted] សិទ្ធ បានធ្វើសកម្មភាពវាយមកលើឈ្មោះ [redacted] ធី ចំនួនមួយដៃចំភ្នែក និងចាប់បោក និងអូសគាត់ទៅប្រឡាយទឹកមុខផ្ទះ ដោយចាប់កគាត់ជ្រមុជទឹកនៅក្នុងប្រឡាយនោះ ដោយសារតែមានឈ្មោះ [redacted] ហំ បានមកជួយឃាត់ ទើបឈ្មោះ [redacted] សិទ្ធ បញ្ឈប់សកម្មភាពនោះវិញ។ បន្ទាប់ពីវាយឈ្មោះ [redacted] ធី រួចឈ្មោះ [redacted] សិទ្ធ ក៏ដើរត្រឡប់ទៅផ្ទះវិញបាត់ទៅ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

**៣.៣.**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងនេះ ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **សិទ្ធ** ហៅក្រៅ **សិទ្ធិ** ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទ: **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ពិតប្រាកដមែន ដូច្នេះតំណាងអយ្យការសូមតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**៣.៤.**លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់អំណានចម្លើយនិងពិភាក្សានាពេលសវនាការនេះមកឃើញថា នៅក្នុងរឿងនេះកូនក្តីខ្ញុំបាទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់នៅក្នុងអង្គហេតុពិតប្រាកដមែនពាក់ព័ន្ធទៅនឹងជម្លោះបាត់ស្បែកជើងម្តាយរបស់ឈ្មោះ [redacted] ធី កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១ ចំពោះសកម្មភាពកូនក្តីខ្ញុំបាទបានប្រើអំពើហិង្សាទៅលើឈ្មោះ [redacted] ធី គឺគាត់ពុំបានគិតនិងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ លើសពីនេះកូនក្តីខ្ញុំបាទគាត់ពុំបានដឹងថាអំពើដែលខ្លួនបានប្រព្រឹត្តនោះវាជាបទល្មើសដែលច្បាប់បានហាមឃាត់ឡើយ។ ហេតុដូច្នេះខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សូមស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់នូវស្ថានសម្រាលទោសឱ្យកូនក្តីខ្ញុំបាទត្រឹមអប្បបរមានមូលទោសពីបទហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម ស្របតាមស្មារតីនៃមាត្រា៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ។

## ៤.សំអាងហេតុ

**៤.១.យល់ឃើញថា:**ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបានពិនិត្យឯកសារនៅក្នុងសំណុំរឿងឃើញថាឈ្មោះ [redacted] **សិទ្ធ** ហៅក្រៅ **សិទ្ធិ** ពិតជាបានប្រព្រឹត្តបទល្មើស **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ពិតប្រាកដមែន។ នេះបើយោងតាម៖

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ:**២០៥** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។



Scanned with CamScanner

- ដីកាសន្និដ្ឋានស្ថាពរលេខ:០៦០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។

- ដីកាដំណោះស្រាយលេខ:០៥៥/២៣ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តឧត្តរមានជ័យ។

**៤.២.យល់ឃើញថា:**តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធី** បានឆ្លើយថា: ឈ្មោះ [redacted] សិទ្ធ បានធ្វើសកម្មភាពវាយខ្លួនមួយដៃចំភ្នែកខាងស្តាំបណ្តាលឱ្យរងរបួសបែកឈាម និងចាប់បោក ព្រមទាំងអូសខ្លួនទៅប្រឡាញខាងមុខ រួចក៏បានចាប់ជ្រមុជទឹកក្នុងប្រឡាយនោះ។ ចម្លើយនេះមានភាពស៊ីសង្វាក់ទៅដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ ដែលបញ្ជាក់បានថាឈ្មោះ [redacted] **សិទ្ធ** ពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ពិតប្រាកដមែន។

**៤.៣.យល់ឃើញថា:**តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ចន្ទី** បានឆ្លើយថា: ឈ្មោះ [redacted] សិទ្ធ បានធ្វើសកម្មភាពវាយមកលើឈ្មោះ [redacted] ធី ចំខ្លួនមួយដៃចំភ្នែក និងចាប់បោក និងអូសគាត់ទៅប្រឡាយទឹកមុខផ្ទះ ដោយចាប់កគាត់ជ្រមុជទឹកនៅក្នុងប្រឡាយនោះ ដោយសារតែមានឈ្មោះ [redacted] ហំ បានមកជួយឃាត់ ទើបឈ្មោះ [redacted] សិទ្ធ បញ្ឈប់សកម្មភាពនោះវិញ។ ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ ដែលបញ្ជាក់បានថាឈ្មោះ[redacted] **សិទ្ធ** ពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ពិតប្រាកដមែន។

**៤.៤.អំពីសំណងរដ្ឋប្បវេណី:**តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលស៊ើបសួរ ឃើញថាបានធ្វើការសុំទាមទារសំណងជំងឺចិត្តចំនួន ១២.០០០.០០០ (ដប់ពីរលាន)រៀល ចំពោះការទាមទារនេះគប្បីតុលាការសម្រេចតាមព្យសនកម្មជាក់ស្តែង។

**៤.៥.អំពីសមត្ថភាពនៃការទទួលខុសត្រូវ៖**យោងតាមសាវតារជាតិរបស់ជនជាប់ចោទឈ្មោះ[redacted] **សិទ្ធ** ភេទប្រុស តុលាការរកពុំឃើញមានឯកសារណាមួយក្នុងសំណុំរឿង នេះដែលបញ្ជាក់ថាជនជាប់ចោទមានវិបល្លាសស្មារតីទេ ដូច្នេះតុលាការសម្រេចឱ្យជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

**៤.៦.**អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សិទ្ធ** ប្រព្រឹត្តឡើងក្នុងចេតនាទុច្ចរិតជននេះជាមនុស្សមានស្មារតីល្អ មានការយល់ដឹងបានច្បាស់លាស់ពីអំពើ និងបច្ច័យដែលបានកើតឡើង ដោយអំពើរបស់ខ្លួនដែលបានប្រព្រឹត្តតែជននេះនៅតែប្រព្រឹត្តបទល្មើស ដែលច្បាប់បានហាមឃាត់មិនឱ្យមានអំពើ **ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមសន្តិសុខសណ្តាប់សាធារណៈ និងអំពើរបស់ជនជាប់ចោទគឺបានខុសពីក្រមព្រហ្មទណ្ឌ។

**៤.៧.**ជនជាប់ចោទ មិនបានចូលខ្លួនក្នុងសវនាការតាមការកំណត់របស់ចៅក្រមជំនុំជម្រះឡើយ និងចំពោះអំពើប្រព្រឹត្តរបស់ជនជាប់ចោទបានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គមជាតិ ហេតុដូច្នេះគប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៤.៨.**ជនជាប់ចោទឈ្មោះ [redacted] **សិទ្ធ** ត្រូវបានចោទប្រកាន់ពីរបទល្មើស យោងតាមមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចប្រកាសទោសតែមួយប្រភេទនៃអតិបរមាដែលខ្ពស់ជាងគេ គឺបទល្មើស **ប៉ុនប៉ងឃាតកម្ម** ។

**៤.៩.** មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] **សិទ្ធ ហៅ សិទ្ធ** ពីបទ:**ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិបុស្សថ្មី សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៦ ខែ



Scanned with CamScanner

សីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៧,១៩៩** និងមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

## ៥.ហេតុដូច្នេះសម្រេច:

**៥.១.**ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សិទ្ធ ហៅ សិទ្ធ** ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន **១០ (ដប់)ឆ្នាំ** ពីបទ:**ហិង្សាដោយចេតនា និងប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅចំណុចភូមិបុស្សថ្មី សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ដែលមានចែងបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា **២៧,១៩៩** និងមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

**៥.២.**បង្គាប់ឱ្យជនជាប់ចោទសងសំណងជម្ងឺចិត្តឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធី** ភេទប្រុស អាយុ៣៥ឆ្នាំ ចំនួន ៩.០០០.០០០ (ប្រាំបួនលាន)រៀល ការទាមទារលើសពីនេះត្រូវច្រានចោល។

**៥.៣.**ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើពិរុទ្ធជនឈ្មោះ [redacted] **សិទ្ធ** ភេទប្រុស អាយុ៣៨ឆ្នាំ យកមកអនុវត្តទោសតាមច្បាប់។

**៥.៤.**ពិរុទ្ធជនឈ្មោះ [redacted] **សិទ្ធ ហៅក្រៅ សិទ្ធិ** មានសិទ្ធិប្តឹងទាស់ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ តាមមាត្រា ៣៦៨ថ្មី ច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ រយៈពេល០១ (មួយ) ខែ តាមមាត្រា៣៨២ ថ្មី ច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៥.៥.**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធី** មានសិទ្ធិប្តឹងទាស់ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ តាមមាត្រា ៣៦៨ថ្មី ច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ រយៈពេល០១ (មួយ) ខែ តាមមាត្រា ៣៨២ ថ្មី ច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សិទ្ធ** ភេទប្រុស អាយុ៣៨ឆ្នាំ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ធី** ភេទប្រុស និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| **ហត្ថលេខានិងត្រា** | **ហត្ថលេខានិងត្រា** | **ហត្ថលេខានិងត្រា** | **ហត្ថលេខានិងត្រា** |

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ០២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

ឧត្តរមានជ័យ,ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner